# កិច្ចសម្ភាសន៍របស់អ្នកមីងឈ្មោះ ជូ សេងគី

កះ អ្នកសម្ភាសន៍ឈ្មោះហេង សុជីវី ខះ អ្នកត្រូវគេសម្ភាសន៍ឈ្មោះ ជូ សេងគី

កះ ជាដំបូងសូមជំរាបសួរអ៊ី!

ខះ ចាស ជំរាបសួរ!

កះ ចាសអ៊ីអគុណច្រើនថ្ងៃនេះដែរខ្ញុំមានឱកាសដើម្បីមកសម្ភាសន៍អ៊ីផ្ទាល់ ហើយអ៊ីមានឈ្មោះអីដែរអ៊ី?

ខះ ខ្ញុំឈ្មោះ ជូ សេងគី!

កះ ហើយអ៊ីមានឈ្មោះក្រៅដែរទេ?

ខះ អត់មានទេ!

កះ ហើយឈ្មោះនិងត្រូវនិងអត្តសញ្ញាណប័ណ្ណទេអ៊ី?

ខះ ចាសត្រូវតើអូន!

កះ ចាសហើយនរណាគេអ្នកដាក់ឲ្យអ៊ីឈ្មោះនិង?

ខះ ប៉ាដាក់ឲ្យ!

កះ ចាស ហើយលោកប៉ានិងអ្នកម៉ាក់របស់អ៊ីឈ្មោះអ៊ីដែរ?

ខះ គាត់ឈ្មោះ ឌិន សឿន ហើយនិងម្ដាយរបស់អ៊ីគាត់ឈ្មោះ ជូ ហេង !

កះ អ៎...ចាស គាត់ទាំងអស់គ្នាប្ដីប្រពន្ធពីរនាក់នៅនិងឬនៅឯណាដែរអ៊ី?

ខះ គាត់នៅនិង នោះនៅផ្ទះខាងនោះ!

កះ អ៎ ....អញ្ចឹងនៅក្បែរគ្នាដែរន៎អ៊ី?

ខះ ចាសនៅជិតគ្នាដែរនឹងអូន!

កះ គាត់នៅមានជីវិតទាំងពីរនាក់ទេអ្នកមីង?

ខ៖ ចាសនៅ!

ក៖ គាត់អាយុប៉ុន្មានហើយសព្វថ្ងៃនេះអ៊ី?

ខ៖ គាត់អាយុ៥០ជាងហើយ!

ក៖ អ៎...!

ខ៖ ម៉ែអាយុ៥៣ប៉ាអាយុ៥៥ហើយ!

ក៖ ចាសហើយអ៊ីមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ បងប្អូនខ្ញុំទាំងអស់មាន៨នាក់អូន!

ក៖ ពួកគាត់មានឈ្មោះអីខ្លះដែរអ៊ី?

ខ៖ ឈ្មោះ សុខ កេង , សុខ គង់ (មានសំលេងរំខាន),សុខលេង និងសេងគា , ស៊ីណា,វាសនានិងរតនាមួយទៀត!

ក៖ បងប្អូនអ៊ីមាន៨នាក់ន៎អីន៎?

ខ៖ ចាស!

ក៖ បងប្អូនអីច្រើនដែរស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរអ៊ី?

ខ៖ បងប្អូនរបស់អ៊ីមានស្រីបួនប្រុសបួនអូន!

ក៖ ពួកគាត់រៀបការអស់ហើយឬនៅអ៊ី?

ខ៖ នៅប្អូនប្រុសរបងអ៊ីនឹងពីរនាក់ទៀតមិនទាន់រៀបការទេ!

ក៖ ចាសអ៊ី!

ខ៖ បើស្រីៗការអស់ហើយ!

ក៖ គាត់បានចូលរៀនទាំងអស់គ្នាតើអ៊ី(មានសំលេងរំខានពីខាងក្រៅ)?

ខ៖ ចាសបានចូលទាំងអស់គ្រាន់ថាបានចេះជាងគេបានតែអាប្អូនទី៧ទេ ទី៦ ទី៧និង វាគ្រាន់បើជាងគេ ហើយមានការងារធ្វើនៅភ្នំពេញតែម្តង!

ក៖ អ៎....ចាស ហើយបងប្អូនផ្សេងទៀតគាត់រៀបការហើយរកស៊ីអស់ហើយន៎ះអ៊ីន៎?

ខ៖ រកស៊ីធម្មតាលក់បន្លែរលក់អីចឹងទៅ(មានសំលេងរំខានពីខាងក្រៅ) ខ្លះចិញ្ចឹមគោ ចញ្ចឹមអីអញ្ចឹងទៅណាស់អូន!

ក៖ នៅជិតនិងដែរន៎អ៊ីន៎?

ខ៖ ចាសនៅជិតនិងដែរអូន!

ក៖ ចុះបងប្អូនអ៊ីមាននៅនិងផងនៅភ្នំពេញផង?

ខ៖ ចាសអូន!

ក៖ អត់មាននៅខេត្តផ្សេងទៀតទេន៎អ៊ី?

ខ៖ អ៎....មាននៅខេត្តផ្សេងៗទៀតមាននៅកំពង់ស្ពឺ និងកោះ ឧញ្ញាតី!

ក៖ អ៎....ចាស! សព្វថ្ងៃនិងអ៊ីមានកូនឬក្រុមគ្រួសារហើយនៅអ៊ីមានហើយន៎?

ខ៖ ចាសមាន!

ក៖ តើប្តីរបស់អ៊ីគាត់ឈ្មោះអីដែរ?

ខ៖ ប្តីរបស់អ៊ីគាត់ឈ្មោះ ម៉ៅ សុខខុន (មានសំលេងក្មេងយំ)!

ក៖ ហើយកូនរបស់អ៊ីទាំងពីរវិញ ?

ខ៖ ឈ្មោះហេង សៀវម៉ី និង ហេង សៀងហ៊ន!

គ៖ មិចដែរ(សំលេងពីខាងក្រៅ)!

ក៖ ចាសហើយគាត់អាយុប៉ុន្មានឆ្នាំហើយអី?

ខ៖ ៥ឆ្នាំនិង៣ឆ្នាំ!

ក៖ អឺ... អញ្ចឹង៥ឆ្នាំគាត់ចូលថ្នាក់មត្តេយ្យហើយនៅ?

ខ៖ ចាសចូលរៀនហើយ!

ក៖ គាត់រៀបនៅសាលាណាដែរអ៊ី?

ខ៖ នេះសាលានៅខាងជើងយើងនេះ!

ក៖ សាលាឈ្មោះអ៊ីដែរ?

ខ៖ ដូចអត់ដឹងឈ្មោះអីទេ ភ្លេចបាត់ហើយអូន( សំលេងកូនក្មេង)!

ក៖ អ៎...ចាស(មានសំលេងរំខាន)!

ខ៖ ដាក់សាលា(មានសំលេងរំខាន)!

ក៖ ចាស!

ខ៖ សាលាខាងខ្ញុំមិនមានសាលាល្អៗទេ(មានសំលេងកូនក្មេង)សាលារៀនពិបាករក!

ក៖ ពិបាករកហ៎?

គ៖ ម៉ាក់?

ខ៖ (ស្តាប់មិនបាន)!

ក៖ ចុះអីមានគំរោងយ៉ាងណាចំពោះការសិក្សារបស់កូន?

ខ៖ ខ្ញុំចង់ឲ្យកូនរៀនបានល្អ មានសំណាងល្អ( សំលេងកូនក្មេង)ហើយមានឡានអីមកយកដល់ផ្ទះសាលាក្បែរផ្ទះចឹងហ្នា ព្រោះអ្នកខ្លះអត់ៗចឹងមានកូនតូចចឹងពិបាករកសាលាល្អណាស់!

ក៖ ត្រូវហើយអ្នកមីង!

ខ៖ (មានសំលេងរំខាន) ហើយខ្លះមានករណីចាប់ក្មេងចាប់អីនិង!

ក៖ អ៎...ចាស!

ខ៖ (សំលេងកូនក្មេង) ហ្អែស!

ក៖ ចាស!

ខ៖ ចង់មានឡានមកយកដល់ផ្ទះមានសាលាក្បែរផ្ទះល្អៗឲ្យកូនរៀន!

ក៖ ចាសត្រូវហើយ(មានសំលេងរំខាន)!

គ៖ ម៉ាក់.....?

ខ៖ ម៉ាក់វៃឥលូវហើយ ដោណាស់!

ក៖ គេកំពុងធ្វើអី កំពុងគូសរូបហ្អែស?

ខ៖ កំពុងសរសេរអក្សរ!

គ៖ ឲ្យមកនេះ!

ខ៖ កូនខ្ញុំរៀនឆ្លាតណាស់ បើបានគ្រូល្អ សាលានៅជិតទៀតខ្ញុំសប្បាយចិត្តប៉ុនរាល់ថ្ងៃពិបាក(មានសំលេងរំខាន)ម៉ាក់វែតលូវហើយ!

ក៖ អឺ...ចាស! សព្វថ្ងៃអ៊ីប្រកបមុខរបរជាអ៊ីដែរ?

ខ៖ ខ្ញុំលក់បន្លែរ លក់បន្លែរនៅផ្សារ បេះបន្លែរពីយើងទៅលក់ទីផ្សារនៅចឹងទៅ យកទៅលក់នៅភ្នំពេញ អត់អីទេកូនប៉ុណ្ណឹងហើយ?

ក៖ បោះដុំមែនទេអ៊ី?

ខ៖ ចាសអូន!

ក៖ មានន័យថាយើងដើរប្រមូលទិញអ្នកស្រុកយើងនៅនេះចឹងទៅ គាត់យកមកលក់ឲ្យយើងអញ្ចឹងទៅហើយយើងយកទៅលក់បន្តរទៀត?

ខ៖ ចាសយកលក់បន្តរទៀត ព្រោះបន្លែរតលូវពិបាកចំណេញណាស់លក់អត់ចេញទេកាលមុនធ្លាប់លក់ បីបួនប្រាំរយគីឡូរតលូវលក់ តែ៥០គីឡូមិនអស់ផង (មានសំលេងកូនក្មេង)តឹងមែនទែន ចេះតែរកៗទៅមិនដឹងធ្វើអីបើយើងមិនចេះអីផង!

ក៖ អំ...!

ខ៖ បើយើងចេះអក្សរអីជ្រៅជ្រះយើងអាចរកការងារល្អបានធ្វើទៅ ចឹងហ្អាសខ្ញុំអត់ចេះអីវាពិបាកចឹង បានលក់បន្លែរតិចតួចនិងទៅ!

ក៖ ចុះមុខរបរមួយនិងយើងធ្វើការចាប់ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរអ៊ី?

ខ៖ ក្រោកតាំងពីរម៉ោង៣ទៅ៣យប់ហ្អាស ម៉ោងបីយប់យើងទៅចឹងទាល់តែម៉ោង១២ឬម៉ោង១អីមានមកដល់ផ្ទះ(មានសំលេងរំខាន)!

ក៖ យប់ៗ?

ខ៖ យប់ៗ!

ក៖ ចាស ដល់ពេល ថ្ងៃទំនេរ?

ខ៖ ទើបទំនេរថ្ងៃនិងទេនិយាយទៅ!

ក៖ (សើច) ចុះរាល់ដង?

ខ៖ រាល់ដងខ្ញុំដល់ម៉ោង៣ខ្ញុំដឹកឥវ៉ាន់ឲ្យគេទៀតហើយអត់បានចូលផ្ទះទេ!

ក៖ អ៎....ចឹងថ្ងៃនិង!

ខ៖ ចាស!

ក៖ សំណាងណាស់បានមកចំចឹង ចំពេលបងស្រីទំនេរ(សើច)!

ខ៖ ទើបបានទំនេរថ្ងៃនិងទេ!

ក៖ ចាស! បន្ទាប់មកមុខរបរមួយនិងអ៊ី ខ្ញុំហៅមិចទេហៅអ៊ីក៏ហៅបង?

ខ៖ បងក៏បានអ៊ីក៏បាន(សើច)!

ក៖ បងតែម្តងទៅចឹង(សើច) បងអាចរកប្រាក់ចំណូលបានប៉ុន្មានតាមរយះប្រាក់ចំណូលនិងដែរ?

ខ៖ បានតិចតួច បានបួនប្រាំម៉ឺនអីនិង?

ក៖ ក្នុងមួយថ្ងៃហ៎បង?

ខ៖ ចាស! មួយថ្ងៃបួននិងប្រាំម៉ឺនសល់!

ក៖ អញ្ចឹងមានន័យថាជាប្រាក់ដែលយើងសល់មិនមែនដើមរបស់យើងមិនមែនចំណាយដើមទៀតទេ?

ខ៖ ចាសទូរទាត់អស់ហើយ សល់លុយយើងចំណេញ( សំលេងកូនក្មេង) បានពីរបីម៉ឺនអីទៅ កាលពីមុនខ្ញុំចំណេញច្រើន!

គ៖ ហើយអង្គុយចាំដល់ហើយ!

ខ៖ កាលមុនបាន១០ទៅ២០ម៉ឺន!

គ៖ ហើយដាក់ពីរកំប៉ុងមើល!

ខ៖ ឥឡូវផាត់ដើមផាត់ចុងរួចរហូតបានពីរបីម៉ឺន(សំលេងកូនក្មេងសើច)!

ក៖ ដោយសារយើងលក់អត់ទាន់អស់មែនទេ?

ខ៖ លក់អស់តែវាមិនបានចំណេញច្រើនក្នុងមួយគីឡូបានតែពីររយបីរយនិង(មានសំលេងរំខាន)!

ក៖ មិចចឹងអ៊ី?

ក៖ ចុះម៉ូយយើងកាលមុនយើងយកទៅឲ្យគាត់ដូចដើមតើ?

ខ៖ និយាយចឹងម៉ូយយើងចឹងជូនកាលទិញតម្លៃថោកចឹងទិញបាន(មានសំលេងរំខាន) តែឥឡូវសំបូរអ្នកទិញវាពិបាក! គេអ្នកម៉ូយបោះដុំគេចំណេញតែពីររយក៏បានដែរបើយើងវិញចំណេញពីររយថ្ងៃក្រោយទៅអស់!

គ៖ អាហ្នឹងវាអញ្ចេកៗ!

ក៖ ចាសត្រូវហើយអ៊ី!

ខ៖ ពិបាកណាស់!

ក៖ ប៉ុន្តែរក្នុងមួយថ្ងៃចឹងអ៊ីដឹកទៅមកប៉ុន្មានគីឡូរដែរ?

ខ៖ និយាយពីបន្លែរយើងហ៎?

ក៖ ចាសអ៊ី!

ខ៖ និយាយទៅ៣០០រយគីឡូ!

ក៖ ៣០០គីឡូហ៎?

ខ៖ ៤០០គីឡូទៅចាស!

ក៖ ច្រើនដែរនិង(សំលេងកូនក្មេង)!

ខ៖ មួយមុខ២០០រយគីឡូ ដូចជាល្ពង១០០គីឡូ អីទៅ និយាយទៅខ្ញុំលក់តែបីមុខល្ពៅ(មានសំលេងរំខាន)!

គ៖ ព្រលប់ៗម៉ែហើយ!

ក៖ ល្ហុង១០០គីឡូល្ពៅ ១០០គីឡូត្រសក់១០០គីឡូចឹងទៅ?

ខ៖ ចាសប៉ុណ្ណឹង!

គ៖ ម៉ោង៨កន្លះអាណា!

ក៖ ចុះបង?

ខ៖ ឥលូវកាត់បន្ថយ!

ក៖ ចុះបងឥលូវធ្លាក់ចុះហ៎បង?

ខ៖ និយាយទៅសម្បូរអ្នកលក់ ហើយរបស់គេនាំចូលច្រើន(មានសំលេងរំខាន)ឲ្យតែរបស់គេនាំចូលច្រើនរបស់ខ្មែរយើងដឹងតែចប់តែម្តង បើរបស់គេកុំនាំចូលរបស់ខ្មែរយើងមិនអីទេ!

ក៖ មិនមែនការផ្គត់ផ្គងរបស់យើងអត់គ្រប់គ្រាន់តែន៎?

ខ៖ (សំលេងកូនក្មេងសើច) មិនមែនទេមកពីរបស់គេនាំចូលច្រើន ឲ្យលុយហើយៗ!

គ៖ ហើយៗ!

ក៖ អញ្ចឹងទេហ៎? អញ្ចឹងមានន័យថាឧទាហរណ៍ថាកសិករយើងខាងកោះចឹងហ្ន៎គាត់បានដាំហើយគាត់បានយកបន្លែរមកលក់ឲ្យបង បងយកតែកំណត់ដែរត្រូវការទេបើលើសនិងក៏បងមិនយកដែរ?

ខ៖ ចាសអូន! បើខ្ញុំយកបានខ្ញុំយកបើខ្ញុំយកទៅលក់មិនបានមិនយកទេ!

ក៖ អ៎.... ស្តាយណាស់អញ្ចឹង ចុះបើពួកគាត់ខំដាំចឹងបើលក់មិនអស់អញ្ចឹងៗមានតែទុកចោលហើយហ៎?

ខ៖ អត់ទេយើង បើសំរាប់អ្នកចំការគ្រាន់តែគ្នាឡើយដាំមែន ប៉ុនដឹងតែគេស្រួលជាងយើងថោកថ្លៃដឹងតែគេយកអស់ៗ បើខ្ញុំវិញបើលក់មិនអស់មានតែចោលដល់អញ្ចឹងយើងខាតនៅលើអាសល់និង បើយើងលក់ឲ្យអស់តែម្តងយើងចំណេញ បើយើងសល់ខាតហើយ!

ក៖ អ្នកចំការដឹងតែបានផលដឹងតែគេយកអស់ហើយ?

ខះ ចាសគេយកអស់ៗ គ្រាន់តែពេលខ្លះអ្នកចំការបើថោកពេកក៏រត់មិនរួចដែរ!

កះ ចាសអ៊ី!

ខះ ជួលឈ្នួលនិងថ្នាំមិនគ្រាន់ផងគ្រាន់តែឈ្នួលបីបួនម៉ឺនបាត់ហើយម្នាក់!

កះ ចាសបងចាស!ហើយអីប្រកបមុខរបរនិងយូរឆ្នាំនៅ?

ខះ យូរហើយប្រហែល៦ទៅ៧ឆ្នាំហើយនិង!

កះ អ៎....!

ខះ តាំងពីរការមកម្ល៉េះ?

កះ អីការប៉ុន្មានឆ្នាំហើយ?

ខះ អីការបាន៦ឆ្នាំហើយ ប្រហែល៦ទៅ៧ឆ្នាំហើយ!

កះ ចាសហើយលោកពូត្រូវជាប្តីអីមានឈ្មោះអីដែរ?

ខះ ឈ្មោះ ម៉ែន សុខា !

កះ គាត់រស់នៅស្រុកនិងតើអ៊ី(មានសំលេងរំខាន)?

ខះ ចាសៗ គាត់នៅស្រុកនិងដែរតើអូន!

កះ កាលអ៊ីរៀបការនិងដោយស្រលាញ់គ្នាឬឪពុកម្តាយជាអ្នកទុកដាក់ឲ្យ?

ខះ កាលនិងស៊ីសងយើងដែរនិងអូន យើងស្រលាញ់គ្នាហើយបានចាស់មកសួរចឹងទៅ!

កះ បានរៀបការតាមផ្លូវច្បាប់អីអញ្ចឹងទៅន៎?

ខះ ចាសបានរៀបការតាមផ្លូវច្បាប់!

កះ អ៊ីបានចាប់ដៃគាត់និងបង្កើតមុខរបរនិងឡើងតែម្តង អត់មានមុខរបរផ្សេងគ្នាទេ?

ខះ អត់មានផងអូន មានតែមុខរបរនិងមួយទេ និយាយទៅគាត់លក់តាំងពីនៅជាមួយម៉ែគាត់មក(មានសំលេងកូនក្មេង)!

កះ អញ្ចឹង៦ឆ្នាំហើយដែរធ្វើមុខរបរមួយនិងឡើង(មានសំលេងកូនក្មេង)!

ខ៖ គាត់លក់យូរហើយតែតាំពីរបានខ្ញុំមកគឺលក់បាន៦ឆ្នាំហើយលក់ជាមួយគ្នាហាស គឺគាត់លក់ជាមួយម៉ែគាត់យូហើយតាំងពីនៅក្មេងមកម្លេះ!

ក៖ អ៎...ចាសអញ្ចឹងបទពិសោធន៍ច្រើនឆ្នាំហើយដែរ?

ខ៖ ចាសច្រើនឆ្នាំ បើខ្ញុំទើបមាននេះទេ!

ក៖ មានម៉ូយអីច្រើនដែរទេនៅភ្នំពេញ?

ខ៖ ម៉ូយអីមិនសូវមានទេអូនអើយ វាអត់មានម៉ូយទេឥលូវវាសម្បូរអ្នកលក់ចឹងបែងចែកគ្នាអស់គហើយ!

ក៖ អឺ...ចាសអឺ.!

ខ៖ ហើយគេរកតែកន្លែងណាថោកទេជាងយើងនិងទៀត!

ក៖ ចាសអឺ ហើយអីមានចង់ប្រកបមុខរបរផ្សេងពីនិងទេ? ឬមុខរបរបន្ថែមអី?

ខ៖ ខ្ញុំចង់ដែរតែមិនដឹងរកអី ចង់រកផ្សេងព្រោះអានិងយើងរកលែងបានចឹងណា!

ក៖ អឺ...ចាស!

ខ៖ ចង់ដូរមុខរបរ មិនដឹងថារកអីបើយើងមិនចេះអីផងនិង!

ក៖ (សើច)!

ខ៖ បើយើងចេះទៅយើងងាយស្រួលរកការងារល្អៗធ្វើចឹងទៅណា!

ក៖ អឺ....!

ខ៖ បើយើងមិនចេះទៅមិចរួច មានតែមុខរបរនិង!

ក៖ និយាយទៅការងារនេះក៏ល្អវាគ្រាន់តែឥលូវអីវ៉ាន់លក់រាងចុះអញ្ចឹង!

ខ៖ ចាំអូន!

ក៖ តើយើងមានវិធីសាស្រ្តអីដើម្បីអោយការលក់យើងបានប្រសើរជាងមុន ដូចជាការបន្ថែមដូចជាដៃគូរសហាការ ដូចម៉ូយអីយើងអញ្ចឹងណា!

ខ៖ ចាសៗអូន!

កៈ រកគាត់បន្ថែមទៅងាយស្រួលបោះឲ្យគាត់បានច្រើនៗ!

ខៈ និយាយទៅរកមិនបានទេព្រោះអ្នកលក់ច្រើនមែនទែនម៉ងណា(មានសំលេងរំខាន) កាលពីមុនខ្ញុំទៅមនុស្សតែពីរទៅបីនាក់ទេ តែឥលូវច្រើនតែម្ដង កាលមុនដំបូងគេទើបការចឹងគេចាប់ផ្ដើមរកដូចយើងអញ្ចឹង ពីដំបូងឃើញយើងរកបានហ្អាស!

កៈ អឺ....ចាស!

ខៈ ដល់អញ្ចឹងគេចាប់ផ្ដើមរកដែរ ដល់ពេលលក់ច្រើនទៅចាប់ផ្ដើមធ្លាក់ទាំងអស់គ្នាដែរ(មានសំលេងរំខាន) កាលពីខ្ញុំការដំបូងណាស់រកបានធ្វើផ្ទះបានសព្វគ្រប់ទិញរបស់របរដែរ(មានសមលេងរំខាន)ដល់ឥលូវរកលែងបាន!

គៈ ឥលូវមានទាន់ហូបអស់ឯណា(សើច)!

កៈ អឺ....!ដោយសារយើងលក់ប្រជែងគ្នា(មានសំលេងរំខាន)!

ខៈ ចាសអូន ប្រជែងគ្នា(មានសំលេងរំខាន)តែដល់ឥលូវនេះបន្លែរនាំមកពីរបស់យួនវានាំចូលមកច្រើនពេក!

កៈ អឺ...ចាសអឺ!

ខៈ អញ្ចឹងរបស់ខ្មែរយើងពិបាករកស៊ីណាស់អូន!

កៈ អឺ....!

ខៈ ដូចជាត្រសក់យើងចាប់ផ្ដើមប្រមូលផលបានគេចាប់ផ្ដើមដល់អញ្ចឹងថោកលក់បានតែមួយគីឡូ ៧០០ទៅ៨០០រយទេ!

គៈ ទៅវិញហើយអ៊ីយ!

កៈ អឺ...(មានសំលេងរំខាន) អឺមានទៅលក់ផ្សារនៅភ្នំពេញនៅម៉ុំណាដែរ? ផ្សារដើមគរឬនៅឯណាផ្សេងទៀត?

ខៈ ផ្សារសាមគ្គីហើយផ្សារសាំហាន់ហួសពីផ្សារដើមគរបន្តិចទៅ!

កៈ (សើច)ខ្ញុំអត់ដែលលឺឈ្មោះនិងទេ ខ្ញុំអត់ដែលដឹង(មានសំលេងរំខាន)!

ខ៖ ផ្សារសាំហាន់ អ៊ីលឺគេផ្សារសាំហាន់អញ្ចឹងដែរ(មានសំលេងរំខាន)!

ក៖ ប្រហែលផ្សារសាមគ្គីនិងដឹង?(មានសំលេងរំខាន)(សើច) ផ្សារសាមគ្គីទេដឹងអ៊ីក្បែរស្ថានអាកាសតិចណូ!

ខ៖
(មានសំលេងរំខាន)នៃផ្សារអីដែលយើងចំណាំទៅលក់ផ្សារសាំហាន់អញ្ចឹងហ្អី(មានសំលេងរំខាន)អ៎ផ្សារជូរី!

ក៖ ផ្សារដែន ជូរីហ៎អ៊ី អូ?

ខ៖ និងហើយផ្សារដែន ជូរី(មានសំលេងរំខាន)!

ក៖ នៅក្បែរព្រលានយន្តហោះ(មានសំលេងរំខាន)!

ខ៖ និងហើយ(មានសំលេងរំខាន)!

ក៖ ចាសខ្ញុំស្គាល់ផ្សារនិងដែរ(មានសំលេងរំខាន)!

គ៖ (សំលេងក្មេងច្រៀង)

ក៖ ហើយចាស(សើច)ហើយមានតែមួយកន្លែងនិងទេន៎អីហ៎?

ខ៖ ចាសលក់តែមួយកន្លែងនិង!

ក៖ មានម៉ូយនៅនិងតែម្តងន៎?

ខ៖ ចាសមានម៉ូយនៅនិង(មានលំលេងរំខាន)បើខ្ញុំដូរផ្សារខ្ញុំលក់រិតតេមិនចេញពេលយើងដូរផ្សារយើងអស់ម៉ូយហើយ(មានសំលេងរំខាន)បើទៅកន្លែងផ្សេងមានម៉ូយឯណាមានតែម៉ូយគេនិង(មានសំលេងរំខាន)!

គ៖ ស្អីគេនិង!

ខ៖ ដល់អញ្ចឹងដូរផ្សារមិនរួចទេបើដូររិតតែអត់ទៀត(សំលេងកូនក្មេង)ហើយលក់មិនចេញ!

ក៖ ហើយទៅម៉ូយរបស់អ៊ីសព្វថ្ងៃមានប៉ុន្មាននាក់ដែរ?(មានសំលេងរំខាន)

ខ៖ មានតិចតូចណាស់អូនប្រហែលប្រាំទៅ៦នាក់អីនិងម៉ូយធំចឹងណា!

ក៖ អឺ.....!

ខ៖
បើម៉ូយតូចៗច្រើន(មានសំលេងកូនក្មេង)ប៉ុណ្ណឹងតិចទេប៉ុន្តែរបន្លែរដល់រាប់រយគីឡូងណោះ!

ក៖ ចាស(មានសំលេងកូនក្មេង)អញ្ចឹងអី!

គ៖ អានេះៗ!

ក៖ ចុះអីមានកន្លែងលក់ខ្លួនឯងនៅផ្សារទេ?

ខ៖ ចាសអូន!

ក៖ មានដែរហ៎?

ខ៖ ចាសមានអូន!(មានសំលេងកូនក្មេង)

ក៖ អឺ...អញ្ចឹងជូលមិចវិញអី?

ខ៖គេជូលមួយព្រឹកៗ
ចឹងទៅគេមកមួយម៉ឺនអីទៅអូន(មានសំលេងរំខាន)ហើយបើយើងបង់ជាខែក៏បានដែរ!

ក៖ អឺ...(មានសំលេងរំខាន)!

ខ៖ បើបង់អញ្ចឹងទៅចំណេញម៉្យាងដែរបើយើងអត់បានទៅលក់វាមិនខាតយើង!

ក៖ ចាសធូរ(មានសំលេងកូនក្មេង)

ខ៖ បើយើងបង់ជាខែគិតសរុបទាំងអស់(មានសំលេងកូនក្មេង)!

ក៖ អឺ....ប៉ុន្តែអញ្ចឹងវាមិនត្រូវដាច់ម៉ូយបើយើងត្រូវយកទៅលក់រាល់ថ្ងៃនិង?

ខ៖ អត់ទេម៉ូយឥលូវវាដើររកតែថោកទេ ទៅត្រង់ណាថោកយកទៅ(មានសំលេងកូនក្មេង)កន្លែងណាថោកមិនគិតម៉ូយណាគេទិញ
រកតែកន្លែងថោកទេបើល្អងលក់មួយគីឡូ៨០០ដើររកកន្លែង៥០០ហើយ(មានសំលេងរំខាន)ព្រោះយើងទិញចូល៥០០ហើយនិងបើលក់៨០០បាន៣០០នៅថ្លៃចិតហើយមួយខាំពីរខាំគេមិនឲ្យយើងទៀត(មានសំលេងរំខាន)គេកាត់ហើយ!

ក៖ អញ្ចឹង?

ខ៖ ផាត់ឲ្យអស់ទៅចំណេញមួយរយចុះមួយគីឡូ(មានសំលេងកូនក្មេង)!

កៈ (សើច)

ខៈ
គេផាត់អស់ទៅ(មានសំលេងរំខាន)(ស្តាប់មិនបាន)ចុះបើយើងធ្លាយកង់ម៉ូតូអីទៅលុយយើងមួយម៉ឺនពីរម៉ឺននិងអស់(មានសំលេងរំខាន)ថ្ងៃមុនគ្រាន់តែធ្លាយកង់អស់មួយអស់(មានសំលេងកូនក្មេង)!

កៈ ចាសៗ(សើច)!

ខៈលក់ឥលូវពិបាកណាស់ខ្ញុំចង់ឈប់ដែរប៉ុន្តែរមិនដឹងរកអី រកមុខរបរផ្សេងមិនបាន!

កៈ អឺ....ចុះអ៊ីខ្ញុំឃើញដូចជានៅជិតផ្ទះអ៊ីមានដាំដើមចំការចេកដែរទេ?

ខៈ ចាសចំការចេករបស់ប៉ាខ្ញុំមានតែចំការខាងក្រោយនិង!

កៈ របស់អ៊ីផ្ទាល់ឬយ៉ាងណាដែរ?

ខៈ របស់ប៉ាខ្ញុំ(មានសំលេងកូនក្មេង)ខាងនេះរបស់គេទេ!

កៈ ចុះពេលបានផលមកអីយកទៅលក់ជាមួយគ្នាទៅមែនទេ(មានសំលេងរំខាន)?

ខៈ
បើរបស់ចេកនិងគេលក់ថ្ងៃសីលៗអញ្ចឹងទៅគេដើរកាប់ទៅដូចចេកបងខ្ញុំអញ្ចឹងឲ្យតែថ្ងៃសីលមានម៉ូយមកកាប់!

កៈ អឺ....!

ខៈ ចេកលក់បានថោកបានតែមួយស្និត១០០០ទេ(មានសំលេងកូនក្មេង)!

កៈ នៅភ្នំពេញឡើង២៥០០រអ៊ីន៎(មានសំលេងកូនក្មេង)!

ខៈ និងហើយ២៥០០ទៅ៣០០០!

កៈ ចាសអញ្ចឹងមិចៗមកទិញនៅនិងវិញ(សើច)ដល់កន្លែងតែម្តង!

ខៈ មកទិញនៅនេះថោក!

កៈ តែដូចជាថ្ងៃនិងអីមានលក់ទេអ៊ី?(មានសំលេងក្មេង)

ខ៖

ថ្ងៃនិងអត់មានទេគេកាប់ទាល់តែថ្ងៃសីលន៎(មានសំលេងរំខាន)បើថ្ងៃសីលដាក់លក់តាមមុខផ្ទះដង្កែរ(មានសំលេងរំខាន)បើខុសថ្ងៃសីលអត់មានទេ!

ក៖ ចាសនិងសំរាប់ចំពោះតែដំណាំចេកទេណ៎អ៊ីន៎?

ខ៖ ចាស(មានសំលេងរំខាន)! បើទៅខាងជើងអត់ថ្ងៃសីលក៏មានដែរ(មានសមលេងរំខាន)អត់ទៀងទេព្រោះចេកគេទុំដើមអញ្ចឹងទៅណា(មានសំលេងកូនក្មេង)ហើយមានគេព្យួរលក់!

ក៖ អ៊ី...ចាសចុះដំណាំផ្សេងៗអីគឺគេប្រមូលរាល់ថ្ងៃតែម្តងមែនទេអ៊ី?

ខ៖ ចាសអូនប្រមូលរាល់ថ្ងៃ ដូចជាត្រសក់ ល្ពុង ននោង អីនិងគេប្រមូលរាល់ថ្ងៃតែម្តង!

គ៖ នៅជាមួយ!

ក៖ គេប្រមូលយកពីរយប់ឲ្យយើងឬក៏យកពីល្ងាចទៅអី(មានសំលេងកូនក្មេង)?

ខ៖ គេប្រមូលតាំងពីល្ងាច!

ក៖ ពីល្ងាចហ៎?

ខ៖ ពីល្ងាចទៅយក!

ក៖ ប្រហែលជាម៉ោងប៉ុន្មានដែរអ៊ី(មានសំលេងរំខាន)!

ខ៖ ប្រហែលម៉ោងបួន ឬបីអីនិងភាគច្រើនម៉ោងបួននិងដើរហើយ!

ក៖ អ៊ី...ចាសត្រូវហើយ ហើយយកមកទុកទៅបានព្រឹកម៉ោង បីអីបានទៅភ្នំពេញ?

ខ៖ ចាសងើបម៉ោងបីទៅ!

ក៖ ចុះកន្លែងកំពង់ចំលងដរគេបើម៉ោងប៉ុន្មាន?

ខ៖ និយាយទៅងើបពីផ្ទះទៅម៉ោងពីរឬពីរកន្លះយើងងើបណា(មានសំលេងរំខាន)ពេលដល់ដរប្រហែលម៉ោងបីបើយើងហួសម៉ោងគេៗចេញចោលយើង បើគេចេញចោលយើងៗមិនអាចទៅលក់កើតទេព្រោះភ្លឺហើយដរចេញចោលយើបានអីឆ្លងទៀត(មានសំលេងកូនក្មេង)!

ក៖ ត្រូវហើយអ៊ី!

ខ៖ ចាសអូន បើភ្លើយើងមកវិញដឹងតែចោលបន្ថែរហើយយើងរិតតែខាតទៀត !

ក៖ អឺ...ចាស!

ខ៖ ព្រោះយើងទៅលក់មិនកើតផង!

ក៖ ធ្វើមិចក្រោកឲ្យទាន់(សើច)!

ខ៖ ចាសម៉ូយៗយប់បើយើងទៅភ្លឺម៉ូយទៅអស់ហើយនិង!

ក៖ ចាសត្រូវហើយអឺ តែដរនិងម៉ោងបីគេបើកន៎?

ខ៖ ចាសម៉ោងបីឆ្លង!

ក៖ តែដរនិងម៉ោងបីគេបើកៗតែម៉ោងបីទេអឺ?

ខ ៖ ម៉ោងពីយើងមកដរបើយើងមានបញ្ហាអីទៅយើងតេហៅគេមកៗហើយ!

ក៖ អ៎....ចាសអឺ!

ខ៖ ដូចជាអ្នកឈឺពោះមានគ្រោះថ្នាក់អញ្ចឹងមានការអីចឹងនិងតេទៅគេមកយកយើងហើយ!

ក៖ អ៎...ចាស!

ខ៖ ប៉ុនម៉ៅដរគេទៅ!

ក៖ ចាស!

ខ៖ បើយើងឆ្លងធម្មតាតែ១០០០រទេ!

ក៖ បើឆ្លងពិសេសប្រហែលប៉ុន្មានទៅ?

ខ៖ ប្រហែល១០ដុល្លា(មានសំលេងរំខាន)!

គ៖ សំលេងក្មេងសើច!

ខ៖ ប៉ុន្តែរបើយើងមានបញ្ហាអ្វីយើងមិនគិតថាថ្លៃឯណា!

ក៖ ត្រូវហើយអឺ!

ខ៖ ចាសអូន!

កៈ អញ្ចឹងគេមាននៅកន្លែងនិងប្រចាំរហូតតែម្តងន៎អ៊ី?

ខៈ ចាសអូន!

កៈ ចាសទាក់ទងជាមួយអាជីវកម្មអ៊ីតាំងពីដើមរហូតមកអ៊ីធ្លាប់មានមុខរបរមុនឡើយ តើអ៊ីធ្លាប់ធ្វើអ្វីក្រៅពីកាដូញដូរមួយនិង មានធ្លាប់ធ្វើការអ្វីផ្សេងទេអ៊ី?(មានសំលេងរំខាន)

ខៈ អត់មានអីផងនិយាយទៅចាប់តាំងពីខ្ញុំចាប់ដៃគ្នារកស៊ីមកប្រកបមុខរបរមួយនិង!

កៈ អញ្ចឹងហ៎?

ខៈ ចាស!

កៈ ចុះអ៊ីបានរៀនដល់កំរិតណាដែរអ៊ី?

ខៈ ខ្ញុំរៀនបានថ្នាក់ទីបីៗជំនាន់និងគ្មានចេះអីផង(មានសំលេងកូនក្មេង)ទីបីចេះតែឡើងចេះតែទៅៗ!

កៈ អឺ...រៀននៅសាលាណាដែរអ៊ី?

ខៈ និងសាលាកន្លែងកូនរៀនដដែលនិងសាលាជួរនិងទៅឃើញសាលាមួយនិង!

កៈ ដឹងឈ្មោះអីទេអ៊ី?

ខៈ និយាយទៅគេដាក់សាលាបង្រៀនគេមិនដឹងដាក់ឈ្មោះសាលាអីផងកើតអីកូន!

កៈ អឺ...!

គៈ (មានសំលេងកូនក្មេង)!

កៈ អឺ...(សើច) ចុះទាក់ទងនិងការរៀននិងមិចអ៊ីរៀនបានត្រឹមថ្នាក់ទីបីឈប់រៀនអញ្ចឹង?

ខៈ និយាយទៅកាលពីនិងខ្ញុំ និយាយទៅរៀនអត់ចូលតែម្តងហើយយើងការងារផ្ទះអញ្ចឹងទំរាំបានទៅរៀនហួសម៉ោងរហូត!

កៈ អឺ...ចាស!

ខ៖ (មានសំលេងរំខាន) ម៉ោង៧ជាងទៅរៀនម៉ោង៨ទៅអញ្ចឹងទៅគេគោរពទង់ជាតិចូលរៀនអស់ទៅ ព្រោះកាលនិងយើងនៅជួយធ្វើការងារម៉ែឪអញ្ចឹងទៅ ជួយអញ្ចឹងទៅ(មានសំលេងរំខាន)!

ក៖ អឺ…!

ខ៖ អត់លុយអត់កាក់ទាល់តែប្រឹងរកបានៗ(មានសំលេងកូនក្មេង)!

ក៖ អឺ…(សើច)!

ខ៖ អញ្ចឹងទៅរៀនមិនចូលតែម្តង!

ក៖ (សើច) ត្រឹមថ្នាក់ទីបីរៀនលែងចូលឈប់រៀនតែម្តង?

ខ៖ ចាសអូន!

ក៖ អញ្ចឹងអីអាចចេះសរសេរហើយអានអក្សរបានដែរទេអ៊ី?

ខ៖ អត់ចេះសសេរផង(មានសំលេងរំខាន)!

ក៖ អត់ចេះភាសាខ្មែរយើងទេមែនអ៊ី?

ខ៖អត់ចេះទេ(មានសំលេងរំខាន)ចេះតែតិចតួចបើឲ្យចេះសរសេរអក្សរអានអក្សរអត់ទេ ហើយអាចសរសេរបានដូចជាឈ្មោះខ្លួនឯងអីនិង!

ក៖ អ៎…ចាសៗ ហើយគិតលេខអីបានទេ?

ខ៖ អត់ទេគិតអត់ចេញទេបើគិតតាមក្បាច់ស្រីអីទៅចេះខ្លះទៅ បើឲ្យបូកលេខបូកមិន គេទិញបន្លែរគេទិញអីបូកមិនចេញទាញកាស្សូ (ម៉ាស៊ីនគិតលេខ) គិតតែម្តង!

ក៖ (សើច)ត្រូវហើយ!

ខ៖ ទាញទូរស័ព្ទចុចតែម្តងទៅ!

ក៖ និងបានវាច្បាស់ជាង!

ខ៖ ចាសអូន!

ក៖ (សើច)!

ខ៖ ចុចមិនស្រួលនិងខុសទៀតណា!

ក៖ ចាសអ្នកមីង!

ខ៖ ចុចប្រញ៉ាប់ពេលដឹងតែចុចមិនចេញហើយ(សើច)!

គ៖ (សំលេងកូនក្មេង)!

ក៖ (សើច) ចុះអីកាលពីក្មេងអីមានធ្លាប់គិតស្រម៉ៃចង់ធ្វើអីដែរ?

ខ៖កាលមុនគិតថា(មានសំលេងកូនក្មេង)ចង់រៀនឲ្យចេះឲ្យបានការងារធ្វើដូចគេអញ្ចឹងហា(មានសំលេងរំខាន)គិតថាធ្វើមិចរៀនឲ្យចេះ(មានសំលេងរំខាន)ប៉ុន្តែរៀនមិនចូល ប្រឹងរៀនអញ្ចឹងរៀនមិនចេះតែម្តង!

ក៖ អឺ...!

ខ៖ ហើយសាលាកាលជំនាន់ខ្ញុំរៀននៅនិងវាក៏ពិបាកទៀត!

គ៖ ៦, ១៥!

ខ៖ គ្រូអត់បានបង្រៀនយើងជិតដល់ទេ (មានសំលេងកូនក្មេង)ដាក់មេលេខឲ្យយើងធ្វើអញ្ចឹងទៅដាក់ចោល សរសេររួចទៅសួរថាយល់អត់?

ក៖ (សើច)!

ខ៖ ធម្មតាយើងក្មេងៗមិនខ្លាចគ្រូរ៉ែ!

ក៖ ត្រូវហើយអឺ!

ខ៖ ហើយមិនឆ្លើយថាយល់!

ក៖ (សើច)!

ខ៖ ថាយល់ទាំងអស់គ្នា!

ក៖ យល់ទាំងមិនយល់(សើច)!

ខ៖
ដល់មកវិញយកសៀវភៅដាក់លើតុគ្រូបោះចោលសៀវភៅតាមបង្អួចអស់រលីង(មានសំលេងរំខាន)!

ក៖ អូ...ចាស!

ខ៖
ស្រុកខ្ញុំអត់បានទេពិបាកទាំងគ្រូពិបាកទាំងសិស្សតែម្តង(មានសំលេងរំខាន)រួចខោអាវយើងទៅរៀនអញ្ចឹងធម្មតាក្មេងមិនលេងដី ម៉េឪរៀបចំទៅពីផ្ទះស្អាតហើយពេលលេងដីលេងអីទៅដៀលសិស្ស(មានសំលេងកូនក្មេង)!

ក៖ អឺ...!

ខ៖
ដៀលថាខោអាវពួកហែងមិនស្មើរក្រណាត់ជូតននាបអញផង(មានសំលេងរំខានពីខាងក្រៅ) វាអញ្ចឹងណា អញ្ចឹងបានថាសិស្សរៀនមិនចេះក៏មកពីគ្រូដែរ អត់បង្រៀនយើងដិតដល់ទេកាលនិងខ្ញុំចាំបាន!

ក៖ អឺ...!

ខ៖ ព្រោះកាលនិងខ្ញុំមិនតូចពេកទេខ្ញុំនៅចាំដែរណា(មានសំលេងកូនក្មេង)មានតូចឯណា!

ក៖ ចាស!

ខ៖
ដៀលយើងទៅមេលេខដាក់ចោលទៅសួរយើង(មានសំលេងរំខាន)ហើយគ្រូសិស្សនិងចេះក៏អត់?ហើយសិស្សឆ្លើយថាចេះ តាមពិតទៅអត់ចេះទេធ្វើមេលេខគ្មានពីណាចេញមួយខុសទាំងអស់!

ក៖ ខ្លាចគ្រូវៃន៎អី?

ខ៖ ខ្លាចគ្រូវៃមិនឆ្លើយថាចេះ!

ក៖( សើច)!

ខ៖ ដល់ពេល!

កៈ ចុះកាលនិងគ្រូមានធ្លាប់វៃមែនអត់បើយើងមិនចេះ?

ខៈ វៃនិយាយទៅវៃទាំងអស់តែម្តង មិនមែនវៃតែម្នាក់ទេ!

គៈ (សំលេងក្មេងយំ)

ខៈ
វៃទាំងអស់ៗអត់មានថាមួយណាធ្វើខុសវៃមួយនិងទេគឺវៃទាំងអស់តែម្តង(សំលេងកូនក្មេង)!បើនិយាយទៅកាលខ្ញុំរៀនគឺវាពិបាកតែម្តង មិនដូលឥលូវទេ ក្មេងឥលូវវារៀនគ្រាន់បើជាងយើងឆ្ងាយណាស់!

គៈ នៅណា!

ខៈ ជំនាន់និងភាគច្រើនអត់ចេះទេ!

កៈ អឺ….!

ខៈ បើរៀនទៅសាលាត្រើយម្ខាងឆ្លងដរហ្មោស (មានសំលេងកូនក្មេង) ហើយទៅខាងកោះឧញ៉ាតី វាគ្រាន់បើ គ្រូគេបង្រៀបានជិតដល់ណាស់ និយាយទៅជេរតែខាងអ្នកខាងសាលានិងទេ ជេរតែខាងនិងជាងគេមួយសាលា ហើយគ្រូមិនសូវយកចិត្តទុកដាក់និងសិស្សហា ហើយគ្រូសម័យនិងកាចៗច្រើនអូន !

កៈ អឺ…ចាស!

ខៈឥលូវគេព្រឹតព្រាងបន្តិចព្រោះមាននាយកគេល្អៗ(មានសំលេងកូនក្មេង)គេមកកាន់កាប់ហា!

កៈ ចាសអឺ!

ខៈ នាយកសាលានៅត្រើយម្ខាងគេមកហើយគ្រូៗទាំងអស់និងក៏ខ្លាចនាយកនិងដែរ ខ្លាចនាយកណាស់ហើយខំប្រឹងបង្រៀនសិស្ស ខំប្រឹងអីថៃសិស្សថៃអី ខ្ញុំទៅមើលពេលយកកូនខ្ញុំទៅរៀនចាប់សិស្សចងសក់ចងអីឲ្យស្អាត កាលមិនមិនអញ្ចឹងទេ!

កៈ (សើច)!

ខៈ មានតែដៀលយើងថែម ឥលូវគ្រូគេចេះច្រើនហើយ!

កៈ ឥលូវគេពង្រឹងគុណភាពការអប់រំច្រើនដែរ ចាសហើយចុះ កាលពីមុនមកដល់ឥលូវអឺធ្លាប់ឆ្លងកាត់បទពិសោធន៍ក្នុងជីវិតមានការលំបាកៗអីគេខ្លះដែរអី?

ខ៖ (មានសំលេងរំខាន) និយាយទៅតាំងពីខ្ញុំដឹងក្តីមកមិនសូវមានពិបាកអីផងអូន បើម៉ែខ្ញុំគាត់រកចំណូលបានគ្រាន់កូនរៀនកូនអីអញ្ចឹងហា ប៉ុន្តែវគ្រាន់តែយើងពិបាកយើងទៅខកម៉ោងយើងធ្វើចំការ ងើបពីយប់ ដូចជាទៅប៉េះដង្កូវប៉េងបោះដង្កូវអីចឹងទៅយើងងើបទៅពីយប់ទៅបេះវា យើងមិនសូវប្រើថ្នាំដូចគេឥលូវនេះទេ!

ក៖ អឺ...ចាសអឺ!

ខ៖ ហើយយើងប្រើជាដៃចាប់វាចេញមក (មានសំលេងកូនក្មេង) ដល់អញ្ចឹងទំរាំតែយើងបានរៀបចំរៀបអីទៅរៀនខកម៉ោងអញ្ចឹងទៅណាអូន!បើឲ្យពិបាកអីអត់មានពីបាកអីផងអូន!

ក៖ អឺ...!

ខ៖ វាមានគ្រប់គ្រាន់ហើយ!

ក៖ ចាសហើយការងារនិងអឺពេញចិត្តជាមួយវាទេ(មានសំលេងកូនក្មេង)? ចូលចិត្តការងារនិងទេ?

គ៖ អញបានហើយ!

ខ៖ ការងារមួយនិងមែន?

ក៖ ចាសអឺ!

ខ៖ (មានសំលេងកូនក្មេង)និយាយទៅមិនសូវសប្បាយចិត្តប៉ន្នានទេវាលំបាករកស៊ី យើងមកយើងផាត់ឲ្យអស់ទៅ វាបានចំណេញតិចពេក (សំលេងកូនក្មេង)និយាយទៅបើយើងមានបញ្ហាអីទៅ យើងដឹងតែពិបាកហើយ ព្រោះចំណូលវាបានតិចពេក ចំណូលតិចពេកពិបាកណាស់អូន!

ក៖ ចាសព្រោះឥលូវចំណូលតិចពេកអីៗក៏ថ្លៃ ឡើងថ្លៃរហូត!

ខ៖ ចាសអូន និយាយទៅបើថ្លៃមិនអីទេ តែវាថោកបើរបស់ឡើងថ្លៃ ដូចជាល្ហុងអីស្រួលវិញទេ!

ក៖ តែទៅទិញឥវ៉ាន់នៅផ្សារថ្លៃៗណាស់៥០០០រអីនិងបានតែបន្តិច(សើច)!

ខ៖ បើយើងទិញតាមតូបគេថ្លៃ!

កៈ ចាសអឺ!

ខៈ បើខ្ញុំជាម៉ូយដុំម៉ូយបោះដុំ ហៅផ្សារបោះដុំហា និងវាថោក ដល់គេទិញពីយើងទៅដាល់លើវាន្តលក់ គេទិញពីយើងទៅតែ១០០០រទេណាគេលក់វិញ២៥០០រទៅ៣៥០០រត្រសក់!

កៈ ចាសអឺ!

ខៈ គេលក់អញ្ចឹង !

កៈ ពាក់កណ្តាលជាង!

ខៈ ចាស ពាក់កណ្តាលជាង (មានសំលេងកូនក្មេង) យើងវិញគ្រាន់តែចំណេញពាក់កណ្តាលដូចគេមិនបានផង បើគេវិញសុទ្ធតែចឹង!

កៈ ចុះអឺបើមានតូបអី(មានសំលេងរំខាន)!

គៈ ហ្អាស?

កៈ នៅនិងទៅស្រណុកខ្ញុំទៅទិញនៅនិងតែម្តង(សើច)!

ខៈ បើយើងជួលតូបអញ្ចឹងក៏ថ្លៃដែរ ជួលគេថ្លៃដែរ!

គៈ ណាគេ?

កៈ តូបអឺធ្លាប់សួរទេជួលមួយថ្ងៃប៉ុន្មានដែរទៅអឺ?

ខៈ លឺគេជួលសុទ្ធតែមួយថ្ងៃ៤ម៉ឺនទៅ៥ម៉ឺនអីន៎អូន គេគិតថ្ងៃដែរខ្ញុំលឺគេមាននិយាយខ្លះៗដែរនិងណា(មានសំលេងកូនក្មេង) បើកន្លែងចែនោះវិញគាត់និយាយថាគ្រាន់តែលក់សោះមួយថ្ងៃ៥០០០០រ ឬ៤០០០០រ បើបងមួយទៀតគាត់ថាតែបួនម៉ឺនទេតែបងមួយទៀតគាត់ថា៥ម៉ឺន!

កៈ អូ...ចាស!

ខៈ អញ្ចឹងវាពិបាកដែរបើយើងលក់បន្លែរក៏ថ្លៃដែរ!

កៈ គេកាត់!

ខៈ បើកន្លែងខ្ញុំលក់រាល់ថ្ងៃតែមួយម៉ឺនទេ!

កៈ ចាសអុឺ(មានសំលេងរំខាន)!

ខៈ បើគេសុទ្ធតែ៣០០០០រទៅ៤០០០០រទៅ៥ម៉ឺនឡើង(មានសំលេងរំខាន)!

កៈ(មានសំលេងរំខាន)ហើយចំពោះបទពិសោធន៍ល្អៗក្នុងជីវិតបងវិញតាំងពីមុនមកដល់ឥលូវនេះតើបងធ្លាប់ជួបគឺអ្វីខ្លះតៅ ហើយពេលណាដែលអុឺសប្បាយចិត្តជាងគេ?

ខៈ រឿងដែលខ្ញុំសប្បាយចិត្តទាល់តែបានរបស់អីដែលធ្វើឲ្យខ្ញុំរំភើបសប្បាយអញ្ចឹងទៅ(មានសំលេងកូនក្មេង)!

កៈ រំភើបនឹកឃើញហើយសប្បាយចិត្តអីចឹងទៅណាមានរឿងអីមួយដែលធ្វើឲ្យអីសប្បាយចិត្តហើយនឹកឃើញហើយសប្បាយចិត្តហើយចងចាំវាមកតាំងពីតូចឬក៏ពីវ័យណាមួយដែលអីចងចាំរឿងនិងមកហើយនឹក(មានសំលេងកូនក្មេង)ឃើញហើយសប្បាយចិត្តតែម្តង?

ខៈ និយាយទៅកាលនៅតូចសប្បាយចិត្តនិងបានជិតចូលឆ្នាំហើយបានដើរលេងសប្បាយ!

កៈ (សើច)!

ខៈ ឬក៏សប្បាយចិត្តបានទិញរបស់អីមួយដែលចូលផ្ទះនាំឲ្យយើងសប្បាយអញ្ចឹង(ស្តាប់មិនបាន)!

កៈ អ៎...! ចុះផ្ទះនេះបងកសាងនៅឆ្នាំណាដែរ?

ខៈ (មានសំលេងកូនក្មេង)បួនឆ្នាំហើយដែលសាងសងផ្ទះនេះ!

កៈ បួនឆ្នាំហើយបងអញ្ចឹងកសាងឆ្នាំ២០០៤ តែឥលូវ២០១៨!

ខៈ ចាស១៤ឆ្នាំហើយអូន!

កៈ ១៤ ឆ្នាំចាស ហើយកសាងក្នុងម៉ូដអីដែរអី?

ខៈ ផ្ទះម៉ូដបុរាណធម្មតានិងអូន!

កៈ អញ្ចឹងហ៎អុឺ?

ខៈ ចាសអូន(មានសំលេងកូនក្មេង)!

កៈ ចាសម៉ូដបុរាណហើយយើងជួលគេធ្វើណាំអីណាំ?

ខៈជួលគេៗ កាលនិងថោក(មានសំលេងរំខាន) ឈ្នួលតែ៦ដុល្លាទៅ៧រយដុល្លា៩(មានសំលលេងកូនក្មេង)បើជួលគេឥលូវឈ្នួលប្រហែល២ពាន់ដុល្លាទៅ៣ពាន់ដុល្លាអីនិង តាមម៉ូដផ្ទះអញ្ជឹងទៅណា!

កៈ ចាសអឺ!

ខៈ ហើយយើងធ្វើម៉ូដមានរៀបក្រោមអញ្ជឹងទៅជាងគេយកថ្លៃតាមនិងទៅបើមិនសូវមានម៉ូដវាក៏ថោកតាមនិងដែរ!

កៈ ចាសអញ្ជឹងផ្ទះនេះម៉ូដវាប៉ុណ្ណឹងគេយក២០០០ដុល្លា?

ខៈ ប៉ុណ្ណឹង៦ទៅ៧រយទេ កាលពីហ្នឹងថោកដល់ឥលូវបើធ្វើម៉ូដ(មានសំលេងកូនក្មេង)អញ្ជឹងចាប់ពី១៣ពាន់ជាង!

កៈ គ្រាន់តែឈ្នួលហាំ?

ខៈ ចាសអូន!

កៈ សំភារៈរបស់យើងទាំងអស់មែនទេអឺ?

ខៈ ចាសរបស់យើងទាំងអស់!

កៈ អញ្ជឹងទំរាំរួចផ្ទះនិងមួយប្រហែលមួយម៉ឺនដុល្លាអីដឹង?

ខៈ បើសិនជាយើងចាក់ដីទៀតវាចូលហើយមួយម៉ឺនៗជាងអីនិង!

កៈ ចាសអឺ!

ខៈ យើងចាក់ដីដាក់ៗវាច្រើន អស់ក៏ច្រើន!

កៈ ប៉ុន្មានឡានដែរអឺដីនេះ!

ខៈ ប្រហែល២០០ឡាន!

កៈ ២០០ឡាន!

ខៈ តែកាលខ្ញុំចាក់វានៅថោកដែរបើដីកាយខ្លួនឯងតែ៥ដុល្លាទេ!

កៈ មួយឡានហ៎?

ខៈ ចាសអូនអាចម៍ដីខ្លួនឯង!

កៈ មានន័យថាយើងយកដីខ្លួនយើងមកចាក់?

ខៈ ចាសដីយើង(មានសំលេងរំខាន)បើយើងទិញគេ២០ដុល្លាអីទៅ!

គៈ ទំពាំងៗ!

កៈ មួយឡាន២០ដុល្លាគុណទៅ២០០ឡាន(សើច)!

ខៈ ចាស២០០ឡានគុណទៅ(មានសំលេងកូនក្មេង)លុយច្រើនដែរ!

កៈ អូ...ចាសហើយដីនេះធំដែរតើទៅដល់ក្រោយទៀតហ៎?

ខៈ ចាសដល់ក្រោយ!

កៈ ក្រោយហ៎!

ខៈ មានអូន!

កៈ ហើយដីទំហំផ្ទះអីនិងមានប៉ុន្មានម៉ែត្រដែរ(មានសំលេងរំខាន)!

ខៈ ទទឹងប្រហែល៩ម៉ែត្របណ្ដោយប្រហែលប៉ុន្មានម៉ែត្រទេភ្លេចដែរ!

កៈ ដប់ម៉ែត្រជាងអីមើលទៅ(មានសំលេងកូនក្មេង)!

ខៈ ប្រហែល២០ម៉ែត្រហើយមើលទៅ!

កៈ វែងដែរអញ្ចឹងចាសអគុណអីច្រើនសំរាបើការសម្ភាសន៍នៅថ្ងៃនិងអញ្ចឹងអឹមានពាក្យពេចន៍អីដើម្បីផ្ដាំផ្ញើរទៅអ្នកដែលបានស្ដាប់សំលេងអឹជាពិសេសកូនចៅរបស់អីផ្ទាល់ដែរទេ(មានសំលេងកូនក្មេង)?

ខៈ ខ្ញុំចង់បានសាលាល្អៗឲ្យកូនខ្ញុំរៀន(មានសំលេងកូនក្មេង)មានគេមកយកកូនយើងដល់ផ្ទះវាបានជិតកុំឲ្យពិបាកភ័យព្រួយថាកូនទៅណាអញ្ចឹងណា!

កៈ ចាស!

ខ៖ ចង់បានសាលាល្អ គ្រូល្អមកមានឡានមានអីមកយកដល់ផ្ទះទៅបានហើយពេលព្រលឹមឡើងយើងរៀបចំកូនយើងឲ្យបានស្អាតហើយឲ្យវាញ៉ាំអីទៅបានឲ្យបានទៅ!

ក៖ ចាស!

ខ៖ នាំចូលសាលាតែម្តង!

ក៖ ចំពោះតំលៃវិញអ៊ីគិតថាបើសិនជាគេយកឡានមកដល់វិញអីគិតថាឲ្យតម្លៃគេប៉ុណ្ណាដែរ!

ខ៖ និយាយទៅពិបាកនិយាយពីតម្លៃដែរ(សើច)!

ក៖ ចាសបើខ្ទង់?

ខ៖ ធ្វើមិចគេយកតែម៉ាគួរសម!

ក៖ គួរសមន៎អ៊ីន៎?

ខ៖ ព្រោះស្រុកទេសយើងយកគួរសមដែលយកទៅណា ប៉ុន្តែរបើយកថោកពេកក៏គ្មានរត់មិនរួចតែបើយកថ្លៃពេកគ្នាដែរមានកូនទៅរៀបអញ្ជឹគ្នាអត់ទៅណា!

ក៖ ចាសអ៊ី!

ខ៖ អញ្ជឹងមានតែយកម៉ាគួរសមអាចទៅបានអញ្ជឹងណា!

ក៖ ចាសៗ!

ខ៖ គួរសមនិងយក!

ក៖ (មានសំលេងកូនក្មេង) អញ្ជឹងសង្ឃឹមថាអនាគតទៅនិងមានឡានមានអីមកយកសិស្សទៅ!

ខ៖ ចាសៗអូន!

ក៖ ដើម្បីបានទៅរៀន!

ខ៖ មានសាលាល្អៗអញ្ជឹងណា!

ក៖ ចាសៗអ៊ី!

ខ៖ ហើយជួយឲ្យកូនយើងបានល្អៗអញ្ជឹងទៅសប្បាយចិត្តហើយ!

ក៖ អគុណអ៊ីសម្រាប់ថ្ងៃនិងអញ្ជឹងអ៊ីមានពាក្យអីសំរាប់ផ្តែរផ្តាំបន្ថែមទៀតទេ?

ខ៖ អស់ហើយមានតែប៉ុណ្ណឹងទេ!

ក៖ ចាសអគុណាច្រើនអ៊ីសំរាប់កិច្ចសម្ភាសន៍នេះ!

ខ៖ ចាសអូន!